# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Apr-2013, 15:59
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧ (៤)នៃវិធានផ្ទៃក្នុង ស្តីពី សារឆ្លងលេខតាមផ្លូវទូតរបស់ សហរដ្ឋអាមេរិក ដែលទើបតែអាចរកបាន នាពេលថ្មីៗនេះ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**ក្រុមមេធាវីការពារក្តី:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Jacques VERGES
លោក Arthur VERCKEN
លោកស្រី Anta GUISSE

# សំណើ

១. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា សូម ដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនូវសារទូរលេខតាមផ្លូវទូតចំនួនម្ភៃប្រាំមួយ ដែលផ្ញើមកពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ និងដែលរដ្ឋមន្ត្រីក្រសួងការបរទេសបានសរសេរនៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥។ នាពេលថ្មីៗនេះ ឯកសារដែលបានប្រកាសថាលែងជាការសម្ងាត់ទៀតហើយទាំងនេះ ត្រូវបានបើក ឲ្យសាធារណៈជនអាចចូលពិនិត្យមើលបានតាមរយៈមូលដ្ឋានគ្រប់គ្រងទិន្នន័យថ្មីមួយដែលអាចឲ្យធ្វើការស្រាវជ្រាវរកបាន ក្នុងនោះមានព័ត៌មានផ្សេងៗ ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការជម្លៀសប្រជាជនចេញដោយបង្ខំ និងការសម្លាប់ពួកទាហានព្រមទាំងមន្ត្រីទាំងឡាយនៃរបបសាធារណៈរដ្ឋខ្មែរ ដែលក្នុងករណីនេះ ជនជាប់ចោទកំពុង ត្រូវបានធ្វើការជំនុំជម្រះក្ដីនៅ ក្នុងសំណុំរឿងលេខ០០២/០១។

*លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកនូវឯកសារដែលទើប រកឃើញថ្មី*

២. វិធាន៨៧(៤)នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យទទួលយកនូវភស្តុតាងថ្មីដែល “មិនអាចរកបាននៅមុនពេលបើកការជំនុំជម្រះក្ដី” ហើយដែល “នាំទៅរកបង្ហាញការពិត”។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា“[]ជាធម្មតា ភាគីដាក់សំណើត្រូវតែបញ្ជាក់ដល់អង្គជំនុំជម្រះថា ភស្តុតាងដែលដាក់ស្នើ គឺពុំទាន់មាននៅឡើយមុនពេលបើកការជំនុំជម្រះ ឬភស្តុតាងនោះនៅពុំទាន់រកឃើញនៅឡើយបើទោះជាខ្លួនខិតខំព្យាយាមយ៉ាងណាក្ដី”[1]។ អង្គជំនុំជម្រះ បានធ្វើការកត់សម្គាល់ថែមទៀតថា “[]គម្លាតនៃពេលវេលារវាងការចាត់វិធានការយ៉ាងសកម្មក្នុងការតាមរកឯកសារ ឬការពន្យាពេលដោយពុំមានការពន្យល់រវាងការរកឃើញទីកន្លែងនៃឯកសារមួយ និងការដាក់ពាក្យសុំទទួលយកឯកសារនោះជាភស្តុតាង អាចបង្ហាញពីការខកខានមិនបានបំពេញការងារ ដោយយកចិត្តទុកដាក់ត្រឹមត្រូវ”[2]។

៣. ឯកសារថ្មីទាំងនេះ គឺបានមកពីមូលដ្ឋានគ្រប់គ្រងទិន្នន័យនៃសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៦ ដែលត្រូវបានប្រកាសថាជាឯកសារសាធារណៈ និងដែលដាក់សម្រាប់ឲ្យសាធារណៈជនអាចរកមើលបាននៅលើគេហទំព័រ WilkiLeaks កាលពីថ្ងៃ

[1] ឯកសារលេខ **E276/2** អនុស្សរណៈដែលមានចំណងជើងថា៖ “ចម្លើយតបទៅនឹងសំណើ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា, នួន ជា, ហើយនិង ខៀវ សំផន,ចុះថ្ងៃទី១០ មេសា ២០១២, ត្រង់កថាខណ្ឌទី៣។

[2] ឯកសារលេខ **E190** សេចក្ដីសម្រេចស្ដីពីឯកសារថ្មី និងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធ,ចុះថ្ងៃទី៣០ មេសា ២០១២, កថាខណ្ឌទី២៣។

ទី៨ ខែមេសា ឆ្នាំ២០១៣។ ឯកសារទាំងនេះត្រូវបានរកឃើញតាមរយៈមូលដ្ឋានគ្រប់គ្រងទិន្នន័យនេះដែលជាប្រធានបទនៃអត្ថបទមួយឈុតរបស់កាសែតដឺខាំបូឌាដេលី និងកាសែតភ្នំពេញប៉ុស្តិ៍ ដែលបានកត់សម្គាល់ថា ឯកសារទាំងនេះ "តាមជាក់ស្តែង នៅមុនពេលផ្សព្វផ្សាយតាមគេហទំព័រ WilkiLeaks នេះគឺមិនអាចឱ្យបើកចូលមើលបានឡើយ" ព្រោះដោយសារឯកសារទាំងនេះគឺជាផ្នែកនៃក្រុមឯកសារមួយដែលក្នុងនោះមានសារទូរលេខតាមផ្លូវទូតចំនួនជាងមួយលានប្រាំពីរសែន (១,៧ លាន) "ដែលអាចឱ្យរកបានតែនៅក្នុងទម្រង់មិនទាន់រៀបរយ (in a raw) និងមិនមានការរៀបចំត្រឹមត្រូវតែប៉ុណ្ណោះ"[3]។ បច្ចុប្បន្ននេះ ឯកសារទាំងនេះត្រូវបាន ដាក់សម្រាប់ឱ្យអាចរកមើលបាន នៅក្នុងមូលដ្ឋានគ្រប់គ្រងទិន្នន័យអេឡិចត្រូនិចតែមួយគត់មួយ ដែលអាចឱ្យស្រាវជ្រាវរកទៅតាមកម្មវត្ថុជាក់លាក់បាន[4]។ ឯកសាររកឃើញថ្មីនៅក្នុងទិន្នន័យនេះគឺជា កម្មវត្ថុនៃអត្ថបទដោយឡែកពីគ្នាដែលនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍នៅចន្លោះរវាងថ្ងៃទី៩ និងទី១២ខែមេសា ២០១៣[5] និងអត្ថបទមួយដែលបានចុះផ្សាយនៅក្នុងកាសែតដឺខាំបូឌាដេលី កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣[6]។

[3] អត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *សារទូរលេខរបស់ គីស្ស៊ីងហ្គ័រ,* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣។ អត្ថបទកាសែត ឌឹខាំបូឌាដេលី ដែលមានចំណងជើងថា *សារទូរលេខរបស់គីស្ស៊ីងហ្គ័រ បញ្ចេញឱ្យដឹងអំពីពេលវេលាដ៏ខ្មៅងងឹតបំផុតរបស់ប្រទេសកម្ពុជា* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣។

[4] អត្ថបទនៅជាយអត្ថបទដែលមានចំណងជើងថា គេហទំព័រ *WikiLeaks 'សារទូរលេខរបស់ឃីស្ស៊ីងហ្គ័រ'* គឺជាការបញ្ចេញឱ្យដឹងដ៏ធំបំផុតដែលពុំធ្លាប់មាន ដែលក្នុងនោះមានឯកសារតាមផ្លូវទូតចំនួនជាង១,៧លាន, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ("ជាជាងការទទួលនូវព័ត៏មានដែលបែកធ្លាយពីប្រភពមួយ សម្រាប់ការបញ្ចេញឱ្យដឹងនេះគេហទំព័រ WikiLeaks បានបង្កើតមូលដ្ឋានគ្រប់គ្រងទិន្នន័យដែលអាចឱ្យធ្វើការស្រាវជ្រាវរកបាននូវឯកសារសាធារណៈនានា. … ដើម្បីធ្វើឱ្យឯកសារនានាកាលពីមុនអាចត្រូវបើកចូលពិនិត្យមើលបាន, គេហទំព័រ WikiLeaks បានទទួលមកនូវរាល់សំណុំឯកសារទាំងអស់មកពីខាងបណ្ណសារ និងការគ្រប់គ្រងឯកសារជាតិ the National Archives and Record Administration (NARA) ហើយបានរៀបចំចងក្រងទៅតាមលំដាប់លំដោយទំព័រនៅក្នុងមូលដ្ឋានគ្រប់គ្រងទិន្នន័យតែមួយដែលអាចឱ្យធ្វើការស្រាវជ្រាវរកបាន")។

[5] អត្ថបទនៅក្របទំព័ររបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *សារទូរលេខរបស់គីស្ស៊ីងហ្គ័រ,* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣។ អត្ថបទរបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *ការវាយប្រហារដោយបង្ហូរឈាមបង្ហាញឱ្យឃើញអំពី... Bloody Strikes Revealed City's Growing Angst,* ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣។ អត្ថបទនៅក្របទំព័ររបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *នល់ មានភាពច្របូកច្របល់អំពីខ្មាំង,បង្ហាញតាមសារទូលេខ, Nol Confused About Enemy, Cables Show*, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣។ អត្ថបទរបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *ការបែកធ្លាយនិយាយប្រាប់ពីរឿងព្រេងនិទានរបស់ឧត្តមសេនីយ៍ចាម, Leaks Tell Cham General's Tale* , ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣។ ("សេចក្តីលម្អិត អំពីព្រឹត្តិការណ៍ តាំងពីយូយារមកហើយនេះត្រូវបានបង្កប់ជ្រៅនៅក្នុងសារទូរលេខតាមផ្លូវទូតរបស់ស.រ.អា ចំនួនរាប់ពាន់ក្នុងកាលពីមុនមកដែលមិនត្រូវបានចាត់ទុកថាជាការសម្ងាត់ទេ ក៏ប៉ុន្តែមិនងាយនឹងអាចចូលទៅពិនិត្យមើលបាន ដែលត្រូវបានចេញផ្សាយកាលពីថ្ងៃច័ន្ទ ដោយគេហទំព័រ WilkiLeaks ដែលជាគេហទំព័រ

៤. ភាពមិនអាចរកមើលបាននៃឯកសារទាំងនេះ កាលពីមុនមកក៏បានបង្ហាញអោយឃើញដោយការពិតផងដែរថា នៅក្នុងចំណោមឯកសារថ្មីចំនួន ២៦ ដែលត្រូវបានដាក់ជូនមកជាមួយសំណើនេះ គ្មានឯកសារថ្មីណាធ្លាប់ត្រូវបានដាក់បញ្ចូលកន្លងមកនៅក្នុងចំណោមឯកសារទាំងឡាយដែលសហចៅក្រមស៊ើបអង្កេត (សចស) បានទទួលមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក នៅក្នុងអំឡុងនៃកិច្ចស៊ើបសួរនោះឡើយ[7]។ លើសពីនេះ សហព្រះរាជអាជ្ញា បានអនុវត្តដោយយកចិត្តទុកដាក់ដោយដឹកនាំធ្វើការស្វែងរកលើគេហទំព័រ WikiLeaks នូវឯកសារនានាដែលពាក់ព័ន្ធនៅក្នុងពេលជាបន្ទាន់បន្ទាប់ពីមានការប្រកាសជូនដំណឹងជាសាធារណៈ អំពីមូលដ្ឋានគ្រប់គ្រងទិន្នន័យនៅក្នុងអំឡុងសប្តាហ៍នៃថ្ងៃទី ៨ មេសា ២០១៣ ហើយដាក់សំណើនេះភ្លាមៗ បន្ទាប់ពីការឈប់សម្រាកបុណ្យចូលឆ្នាំថ្មី។ ហេតុនេះ សហព្រះរាជអាជ្ញា សូមជូនជាមតិដើម្បីពិចារណាថា មានមូលហេតុដ៏ល្អសម្រាប់អោយទទួលយកនូវឯកសារទាំងនេះ ស្របទៅតាមលក្ខណៈវិនិច្ឆ័យដែល អង្គជំនុំជម្រះសាលាដំបូងបានបង្កើតឡើងសម្រាប់ការទទួលយកនូវឯកសារថ្មី អនុលោមតាមវិធាន ៨៧(៤)។

*លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកអនុលោមតាមវិធាន ៨៧(៣)*

៥. ភស្តុតាងថ្មីក៏ត្រូវតែបំពេញលក្ខខណ្ឌអោយបានសព្វគ្រប់ផងដែរ “បទដ្ឋានស្តីពីភាពជាប់ទាក់ទងភាពគួរអោយជឿទុកចិត្តបាននៃ*ភស្តុតាងដែលគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* និងយថាភាពដែលបានតម្រូវ ក្រោមវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង”[8]។

---

ប្រឆាំងនឹងការសម្ងាត់”)។ អត្ថបទរបស់កាសែតភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា *ការបែកធ្លាយដែលបង្ហាញពីការបរាជ័យ, សេចក្តីសង្ឃឹមខុស Leaks Show Failures, False Hope*,, ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣។

[6] អត្ថបទនៅក្របទំព័ររបស់កាសែតដឺខាំបូឌាដេលី ដែលមានចំណងជើងថា “*សារទូរលេខរបស់គីស្ស៊ីងហ្គ័រ បញ្ចេញឱ្យដឹងអំពីពេលវេលាដ៏ខ្មៅងងឹតបំផុតរបស់ប្រទេសកម្ពុជា” ‘Kissinger Cables’ Reveal Cambodia’s Darkest Hours*, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ (“ឯកសារតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកជាច្រើនរយពាន់ទំព័រ តាំងពីទសវត្សរ៍ឆ្នាំ១៩៧០មក ដែលកាលពីមុនចាត់ទុកជាការសម្ងាត់, ត្រូវដាក់ផ្សាយតាមគេហទំព័រដែលអាចបើករកមើលបានតាម WikiLeaks កាលពីម្សិលម៉ិញ, បានផ្តល់ជូននូវការយល់ដឹងជ្រៅជ្រះអំពីចំណុចដែលធ្វើឱ្យមានការប្រែប្រួលនៃប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា ដែលកាលពីមុនមកមើលមិនឃើញ”)។

[7] ឯកសារនានាកាលពីមុនដែលសហចៅក្រមស៊ើបអង្កេតបានទទួលមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក និងពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២ រួចហើយ ដើម្បីចូលជាផ្នែកនៃឃុតឯកសារលេខ D291, D313, D366 ឬ D248។ ឯកសារនានាសម្រាប់ពេលជំនុំជម្រះក្តីត្រូវបានជ្រើសរើសមកពីក្រុមនេះ ត្រូវបានដាក់បញ្ចូលនៅក្នុឧបសម្ព័ន្ធទី១៧ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៨០(៣)(ឃ)នៃវិធានផ្ទៃក្នុង។

[8] ឯកសារលេខ **E276/2** អនុស្សរណៈដែលមានចំណងជើងថា៖ “ចម្លើយតបទៅនឹងសំណើ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា, នួន ជា, ហើយនិង ខៀវ សំផន,ចុះថ្ងៃទី១០ មេសា ២០១៣, គ្រង់កថាខណ្ឌទី២។

៦. ភាពគួរអោយជឿទុកចិត្តបាន និងយថាភាពនៃសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកដែលបានដាក់ជូនមកជាមួយសំណើនេះ ត្រូវបានបង្ហាញដោយខ្នាតទំហំនៃឯកសារនានា និងទិន្នន័យនៃអត្តសញ្ញាណដែលបានដាក់បញ្ចូលនៅក្នុងឯកសារនីមួយៗ ដែលស្របគ្នាជាមួយនឹងឯកសារត្រូវបានប្រកាសថាជាសាធារណៈផ្សេងៗទៀតរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយករួចហើយ ។ ឯកសារនីមួយៗក្នុងចំណោមឯកសារទាំងឡាយដែលបានដាក់ជូន គឺចាប់ផ្តើមដំបូងដោយសេចក្តីសង្ខេបនៃពត៌មាន មកពីមូលដ្ឋានគ្រប់គ្រងទិន្នន័យ (ដែលមាន fields ជាអក្សរដិតក្រាស់) ចែកដាច់ពីគ្នាដោយបន្ទាត់មួយមកពីអត្ថបទសារទូរលេខដើម។ សារទូរលេខច្បាប់ដើមសុទ្ធតែសរសេរជាអក្សរធំទាំងអស់ ហើយចាប់ផ្តើមដោយក្បាលទំព័រវែងៗ ក្នុងនោះរួមមាន៖ ចំណាត់ថ្នាក់ដើមរបស់ឯកសារ, លេខទំព័រ, កាលបរិច្ឆេទ, ប្រភពនៃឯកសារ, រាល់ការិយាល័យទាំងអស់ដែលត្រូវផ្ញើជូន, និងបន្ទាត់មួយចំនួនសម្រាប់ "ផ្លាកឈ្មោះ Tags" និងកម្មវត្ថុនៃសារទូរលេខ។ ខ្នាតទំហំដាច់ដោយឡែកមួយត្រូវបានប្រើប្រាស់ សម្រាប់កាលបរិច្ឆេទ (ឧទាហរណ៍ដូចជា "P R 021150Z APR 74")។ សេចក្តីយោងទៅលើអក្សរកាត់ តាមរបៀបជរលេខ (Steno) និង អក្សរឬលេខសម្ងាត់ដោយឡែក ក៏ត្រូវបានប្រើប្រាស់ផងដែរ។ ឧទាហរណ៍ដូចជា ក្បាលទំព័រនៃរាល់ឯកសារទាំងអស់ ផ្ញើមកពីស្ថានទូតអាមេរិកប្រចាំកម្ពុជាគឺ "FM AMEMBASY PHNOM PENH"។ សារទូរលេខតាមផ្លូវទូតនីមួយៗក្នុងចំណោមសារទូរលេខតាមផ្លូវទូតនានា ក៏មានបន្ទាត់មួយនៅក្បែរកន្លែងចាប់ផ្តើមនៃក្បាលទំព័រដោយអក្សរឬលេខសម្ងាត់ដោយឡែកផងដែរ ដូចជា "ACTION EA-14", "ACTION AID-59" ឬ "ORIGIN EA-14"។ យថាភាពអាចត្រូវបានបញ្ជាក់ដោយការប្រៀបធៀបខ្នាតទំហំនៃឯកសារទាំងឡាយដែលបានដាក់ជូន ទៅនឹងសារទូរលេខតាមផ្លូវទូតផ្សេងៗទៀតដែលបានទទួលដោយផ្ទាល់មកពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ត្រូវបានអង្គជំនុំជម្រះទទួលយករួចហើយដូចជា របាយការណ៍ប្រចាំសប្តាហ៍មកពីស្ថានទូតសហរដ្ឋអាមេរិក មានចំណងជើងថា "របាយការណ៍ស្តីពីប្រទេសខ្មែរ"[9] និងរបាយការណ៍ជាប្រក្រតី ដែលផ្ញើមកដោយរដ្ឋមន្ត្រីក្រសួងការបរទេស សហរដ្ឋអាមេរិក ដែលមានចំណងជើងថា "សេចក្តីសង្ខេបព័ត៌មាននៃសារព័ត៌មាននានារបស់ស្ថានទូត ស.រ.អា EA Press Summary"[10]។

៧. ភាពជាប់ពាក់ព័ន្ធនៃឯកសារដែលបានដាក់ជូន ត្រូវបានបង្ហាញនៅក្នុង ឧបសម្ព័ន្ធក ដែលក្នុងនោះមានការពិពណ៌នាអំពីឯកសារនីមួយៗ និងអំពីផ្នែកនៃដីកាដំណោះស្រាយដែលឯកសារនេះមានជាប់ទាក់ទង។ ឯកសារទាំងនេះមានជាប់ពាក់ព័ន្ធជាពិសេសទៅនឹងឧក្រិដ្ឋកម្មស្នូលនានានៅក្នុង

[9] ឧទាហរណ៍ អំពីរបាយការណ៍ប្រចាំសប្តាហ៍មួយចំនួនរបស់ស្ថានទូតសហរដ្ឋអាមេរិក ស្តីពីប្រទេសខ្មែរ ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយក នោះគឺ៖ ឯកសារលេខ **E3/3294** (D313/1.2.268), ឯកសារលេខ **E3/3305** (D313/1.2.30), ឯកសារលេខ **E3/195** (D313/1.2.32) និង ឯកសារលេខ **E3/3334** (D313/1.2.49)។

[10] ឧទាហរណ៍ អំពីសេចក្តីសង្ខេបព័ត៌មានរបស់សារព័ត៌មាននានាមួយចំនួនរបស់ស្ថានទូតសហរដ្ឋអាមេរិកដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយក នោះគឺ៖ ឯកសារលេខ **E3/3312** (D313/1.2.34), ឯកសារលេខ **E3/194** (D313/1.2.38), ឯកសារលេខ **E3/3551** (D366/7.1.727) និង ឯកសារលេខ **E3/3343** (D313/1.2.66)។

សំណុំរឿងលេខ ០០២/០១ ការជម្លៀសប្រជាជនកម្ពុជា ដោយបង្ខំ ការធ្វើបាបប្រជាជនដែលធ្លាប់រស់នៅតាមទីក្រុងនិងទីប្រជុំជននានាដោយចាត់ទុកថាជាខ្មាំង និងការសម្លាប់ដោយការផ្តោតមុខសញ្ញាទៅលើពួកមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។

៨. ឧទាហរណ៍ដូចជា ឯកសារមួយចំនួនរៀបរាប់អំពីការវាយប្រហារដោយកងកម្លាំងនៃបក្សកុម្មុយនិស្តកម្ពុជា(បកក) ទៅលើទីក្រុង និងទីប្រជុំជននានាផ្សេងទៀតដូចជា កំពង់ចាម និងឧដុង្គ ដែលក្នុងនោះប្រជាជនស៊ីវិលត្រូវបានបង្ខំដោយអំពើហិង្សាអោយចាកចេញពីផ្ទះសំបែងរបស់ពួកគេ ហើយជម្លៀសអោយទៅនៅតាមតំបន់ដែលកាន់កាប់ត្រួតត្រាដោយ បកក (ឧទាហរណ៍ដូចជា ឯកសារលេខ ១-៩, ១៧)។ របាយការណ៍មួយចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៧៣ មានចំណងជើងថា "ផលប៉ះពាល់នៃការវាយប្រយុទ្ធគ្នាដើម្បីដណ្តើមយកកំពង់ចាម" (ផ្អែកលើមូលដ្ឋាននៃការធ្វើទស្សនកិច្ចមួយទៅកាន់ទីក្រុងដោយមន្ត្រីស្ថានទូតចំនួនបីរូប) បានថ្លែងថាៈ កងកម្លាំងរបស់ បកក "បានបាញ់គ្រាប់រ៉ុក្កែត និងគ្រាប់ផ្លោង សំដៅឲ្យចំៗផ្ទះសំបែង ប្រយោជន៍ដើម្បីបង្ខំអ្នកស្នាក់នៅដែលពួនលាក់ខ្លួនក្នុងលំនៅដ្ឋានអោយចាកចេញ" និងថា "ជនទាំងឡាយដែលនៅរស់ជីវិត បន្ទាប់មកទៀតត្រូវបានគេប្រមូលផ្តុំដោយបែងចែកទៅតាមអាយុ, មុខរបររកស៊ី, ជាដើម ហើយអោយដើរចេញពីទីក្រុង"។ របាយការណ៍មួយបន្ថែមទៀត កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៣ បានយោងទៅលើ "របាយការណ៍របស់សាក្សីដែលឃើញផ្ទាល់ភ្នែក អំពីការសម្លាប់គ្រូបង្រៀននៃសាលាបឋមសិក្សា និងការសម្លាប់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យ ការផ្សឹកលោកសង្ឃ" ដោយបានកត់សម្គាល់ថា បន្ទាប់ពីរដ្ឋាភិបាលបានចូលកាន់កាប់ត្រួតត្រាកំពង់ចាមជាថ្មីឡើងវិញ គ្រូ ចំនួនមួយពាន់ពីររយនាក់ ក្នុងចំណោមគ្រូសាលាបឋមសិក្សារបស់ទីក្រុងនេះចំនួនពីរពាន់នាក់បានបាត់ខ្លួន មន្ត្រីរដ្ឋការចំនួនហុកសិបនាក់ក្នុងចំណោមមួយរយនាក់ដែលមកពីមន្ទីររដ្ឋបាលខេត្ត ត្រូវបានខ្មាំងចាប់ខ្លួន ហើយនិងមានចំនួនជនស៊ីវិលរហូតដល់បីម៉ឺនទៅបួនម៉ឺននាក់ ត្រូវបានចាប់ពង្រត់យកទៅដោយ បកក។ របាយការណ៍មួយចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៤ បានរៀបរាប់អំពីការដួលរលំនៃក្រុងឧដុង្គ ធ្លាក់ចូលទៅក្នុងដៃរបស់កងកម្លាំង បកក នៅក្នុងថ្ងៃនោះ ដែលរួមទាំងការខូចខាតនៅក្នុងចំណោមប្រជាជនស៊ីវិល និងរបាយការណ៍មួយបន្ថែមទៀត ពីរថ្ងៃក្រោយមកទៀត បានកត់សម្គាល់អំពីការសង្កេតការណ៍ពីលើអាកាស ទៅលើ "ប្រជាជនដែលកំពុងត្រូវបាននាំចេញទៅកាន់ទិសនិរតី"។ ឯកសារជាបន្ទាប់មកទៀត ចុះថ្ងៃទី២ខែមេសា ឆ្នាំ១៩៧៤ និងទី១៧ខែកក្កដា ឆ្នាំ១៩៧៤ រៀបរាប់អំពីរបាយការណ៍នានា និងបង្ហាញភស្តុតាងអំពីអំពើដ៏សាហាវព្រៃផ្សៃនានា បានប្រព្រឹត្តឡើងដោយកងទ័ពរបស់ បកកប្រឆាំងនឹងពួកទាហាន ហើយនិងជនស៊ីវិល ដែលគេចាប់បាននៅឧត្តុង្គ។

៩. ភស្តុតាងបន្ថែមទៀតអំពីផែនការណ៍ និងគោលនយោបាយរបស់ បកក ចំពោះប្រជាជនអ្នកទីក្រុងនៃប្រទេសកម្ពុជា និងជនប្រកែកមិនព្រមចូលរួម ឬគាំទ្រដល់ បកក ត្រូវបានផ្តល់ដោយរបាយការណ៍នានា រៀបរាប់អំពីការបំលាស់ទីនៃជនភៀសខ្លួន និងអំពីការវាយប្រហារដោយគ្រាប់រ៉ុកែតរបស់ បកក ទៅលើប្រជាជនស៊ីវិលនៃទីក្រុងភ្នំពេញនិងទីក្រុងផ្សេងៗទៀត។ ការបាញ់

គ្រប់ផ្តោងចូលទីក្រុងកំពត ក្នុងខែមីនា និងមេសា ឆ្នាំ១៩៧៤បានបណ្តាលឲ្យស្លាប់និងរបួសជនស៊ីវិលយ៉ាងច្រើន ហើយបានបង្កើតជាជនភៀសខ្លួនថ្មីចំនួន៨ពាន់នាក់ ដោយប្រជាជនបានភៀសខ្លួនចេញទីតំបន់ដែលបានវាយប្រហារដោយ បកក (ឯកសារលេខ៤ និងលេខ១១)។របាយការណ៍មួយរបស់ស្ថានទូតអាមេរិកចុះថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ១៩៧៤ មានចំណងជើងថា៖ "ការហូរចូលនៃជនភៀសខ្លួនទៅក្នុងបណ្តាខេត្តនានា" បាននិយាយថា អ្នកភូមិចំនួនជាង២៧.៥០០នាក់បានភៀសខ្លួនមកពីតំបន់នានាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ កបប នៅក្នុងអំឡុងពេលជាច្រើនសប្តាហ៍កន្លងទៅនេះ។ ពួកជនភៀសខ្លួនទាំងនេះបានរាយការណ៍ថា បកក បាន "បង្ខំដោយប្រើកម្លាំងឲ្យពួកអ្នកភូមិជាច្រើនទៅតាំងទីលំនៅថ្មីនៅតំបន់ដែលលំបាករស់នៅ Hinderlands" អាហារហូបចុកមិនគ្រប់គ្រាន់ពីព្រោះ "រាល់ភោគផលទាំងអស់ត្រូវផ្តល់ទៅឲ្យបណ្តាសហករណ៍នានាដែលរៀបចំឡើងដោយពួកឧទ្ទាម", "ជម្ងឺដំកាត់ផ្សេងៗមានភាពរីករាលដាល","រាល់ពិធីបុណ្យតាមសាសនាឬពិធីបុណ្យនានាត្រូវបានហាមឃាត់",ហើយ "ការទិទៀនមិនត្រូវបានអត់ឱនឲ្យឡើយ ហើយជនទាំងឡាយណាដែលបានរអ៊ូរទាំ ករណីភាគច្រើនៗបញ្ជូនទៅឲ្យអង្គការថ្នាក់លើ ហើយ មិនដែលឃើញជាសារថ្មីម្តងទៀតទាល់តែសោះ"(ឯកសារលេខ៣)។

១០. របាយការណ៍មួយចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៥ មកពីស្ថានទូតអាមេរិកដែលមានចំណងជើងថា៖ "ស្ថានភាពនៃជនភៀសខ្លួននៅពេលចាប់ផ្តើមដំបូងនៃការវាយប្រហារនៅកំពង់ចាមថ្មីៗនេះ "បាននិយាយថា បកកបានធ្វើការវាយប្រហារនៅជុំវិញក្រុងភ្នំពេញ បានបង្ខំឲ្យប្រជាជនជាង១៣.០០០នាក់បោះបង់ចោលផ្ទះសំបែង ហើយភៀសខ្លួនទៅកាន់រដ្ឋធានី ហើយថា ជនភៀសខ្លួនជាច្រើនដែលត្រូវកងកម្លាំងរបស់ បកក ចាប់បាន ត្រូវបានពួកវាសម្លាប់ "នៅនឹងកន្លែងតែម្តង"។ សារទូរលេខមួយចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៥ មកពីស្ថានទូតសហរដ្ឋអាមេរិកបានរាយការណ៍ថា "នៅក្នុងអំឡុងពេល១២ថ្ងៃកន្លងទៅនេះ មានគ្រាប់រ៉ុកែតធុន១០៧មីល្លីម៉ែត្រចំនួន១០០គ្រាប់ ត្រូវបានបាញ់ទៅលើតំបន់ទីក្រុងនិងអាកាសយានដ្ឋាន ដែលក្នុងនោះមានគ្រាប់រ៉ុកែតជាច្រើនគ្រាប់បានធ្លាក់ទៅចំតំបន់ដែលមានប្រជាជនរស់នៅយ៉ាងកកកុញ"ដូចជា នៅផ្សារថ្មី ជាដើម។ កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ស្ថានទូតអាមេរិកបានរាយការណ៍ ថា មានកុមារចំនួន ៨នាក់ត្រូវបានសម្លាប់ និង៥០នាក់ទៀតបានរងរបួសដោយសារការវាយប្រហារដោយគ្រាប់រ៉ុកែតរបស់ បកកដែលបានធ្លាក់ទៅចំសាលារៀនមួយ ស្ថិតនៅក្បែរស្ថានីយ៍រថភ្លើងក្រុងភ្នំពេញ។ របាយការណ៍មួយ ស្តីពីសភាពការណ៍នៃជនភៀសខ្លួន ចុះថ្ងៃទី៨ខែកុម្ភៈ ឆ្នាំ១៩៧៥ បានរៀបរាប់អំពីការវាយប្រហារមួយដោយកងកម្លាំងរបស់ បកក ទៅលើជំរុំជនភៀសខ្លួនទួលត្រាច នៅក្នុងខេត្តកំពង់ស្ពឺដែលក្នុងការវាយប្រហារនោះបានធ្វើឲ្យឆេះជំរុំ និងអ្នកភូមិចំនួន១០នាក់ស្លាប់ ដែលក្នុងនោះរួមមានកុមារចំនួន៦នាក់ដែលត្រូវបាន "សម្លាប់យ៉ាងកំរោលដោយប្រើកាំបិត និងចំពុះទុង បន្ទាប់ពីត្រូវចាប់បាន"។ នៅក្នុងរបាយការនេះបានកត់សម្គាល់ថា បកក បានដុតបំផ្លាញ ភូមិស្ថានដែលបានតាំងទីលំនៅថ្មី របស់ជនភៀសខ្លួនអស់ "ជាច្រើនកន្លែង" ចាប់តាំងពីខែតុលា ឆ្នាំ១៩៧៤មក ដែលជាផ្នែកនៃយុទ្ធសាស្ត្រ ដើម្បីដាក់ទណ្ឌកម្មដល់ពួកជនស៊ីវិលទាំងឡាយ ប្រកែកមិនព្រមចូលរួម

ជាមួយ កបប ។ ហើយបាននិយាយថា កងកម្លាំងរបស់ បកក បានធ្វើមិនដឹង មិនឮ ចំពោះទីតាំងការពារនានា របស់កងយោធពលខេមរៈជាតិ (FANK) ហើយផ្ទុយទៅវិញ បែរជា "[]ប្រមូលផ្តុំការវាយប្រហាររបស់ខ្លួនទៅលើភូមិនានា ដោយបាញ់កាំភ្លើងរបស់ខ្លួនមិនតម្រង់ទៅលើពួកទាហានទេ តែតម្រង់ទៅលើពួកអ្នកភូមិទៅវិញ"។ ឯកសារទាំងនេះជួយនៅក្នុងការបង្ហាញភស្តុតាងអំពីគោលបំណងនៃការវាយប្រហាររបស់ បកក ទៅលើទីបណ្តាក្រុង និងទីប្រជុំជននានា ហើយបដិសេធមិនព្រមវាយប្រហារទៅលើទីតាំងការពារ ដូចដែល បកក បានមានគោលដៅផ្តែកមនុស្សធម៌ ឬមានបំណងចំពោះប្រជាជនស៊ីវិល និងប្រជាជនភៀសខ្លួននៃទីក្រុងភ្នំពេញនោះឡើយ។

១១. ឯកសារមួយក្រុមទៀត ជួយនៅក្នុងការបង្ហាញភស្តុតាងថា ខៀវ សំផន និងអៀង សារី បានបញ្ចប់ការធ្វើដំណើរនៅបរទេសរបស់ខ្លួន ហើយបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ ទាន់ពេលវេលាសម្រាប់កិច្ចប្រជុំគណៈកម្មាធិការមជ្ឈឹម ដែលនៅពេលនោះបញ្ហាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានលើកយកមកពិភាក្សានិងសម្រេច។ របាយការណ៍ស្តីពីប្រទេសខ្មែរចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៤ របស់ស្ថានទូតអាមេរិកបានរាយការណ៍មកថា គណៈប្រតិភូរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលដឹកនាំដោយ ខៀវ សំផនដែលទើបតែបានធ្វើទស្សកិច្ចនៅបណ្តាប្រទេសចំនួន១១រួចមក បានវិលត្រឡប់ទៅកាន់ទីក្រុងប៉េកាំងវិញកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៤ ដោយសម្តែងការភ្ញាក់ផ្អើលចំពោះ "ការបញ្ចប់នូវដំណើរទស្សនៈកិច្ចនេះដែលហាក់ដូចជាឆាប់រហ័សណាស់"(ឯកសារលេខ១០)។ របាយការណ៍ជាបន្តបន្ទាប់មកទៀតចំនួនមួយឃុតដែលចងក្រងជាឯកសារអំពីពេលវេលា នៃការវិលត្រឡប់ពីដំណើរទស្សនកិច្ចរបស់ ខៀវ សំផន មកកាន់កម្ពុជាវិញ កត់សម្គាល់ថាគាត់បានមកដល់ទីក្រុងហាណូយនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៤(ឯកសារលេខ១២), បានទៅធ្វើទស្សនៈកិច្ចនៅទីបញ្ជា ការធំរបស់ប៉ាថេតឡាវ នៅក្នុងខេត្តសំនឿ ចាប់ពីថ្ងៃទី២ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៤ "នៅតាមផ្លូវនៃការធ្វើមាតុភូមិនិវត្តន៍របស់គាត់ពីប្រទេសចិន មកកាន់ប្រទេសកម្ពុជាវិញ"(ឯកសារលេខ១៤ នឹងលេខ១៥) ហើយបានឈប់សំចតនៅតំបន់រំដោះក្វាទ្រី ចាប់ពីថ្ងៃទី១១ដល់ទី១៣ខែមិថុនា ឆ្នាំ១៩៧៤ មុនពេលវិលត្រឡប់ជាចុងក្រោយបង្អស់មកដល់ទឹកដីកម្ពុជាវិញ(ឯកសារលេខ១៦)។ អៀង សារី បានទទួលយល់ព្រមលើករណីនេះថា គាត់បានវិលត្រឡប់មកកម្ពុជាវិញនៅក្នុងឆ្នាំ១៩៧៤[11] ហើយ ភី ភួនបានផ្តល់សក្ខីកម្មថា អៀងសារីបានវិលត្រឡប់មកប្រទេសវិញនៅក្នុងឆ្នាំ១៩៧៤ ដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំរបស់មជ្ឈិមបក្ស ដែលបានធ្វើឡើងនៅក្នុងខែមិថុនា ឬកក្កដា ដែលនៅពេលនោះខៀវ សំផន និង នួន ជាក៏បានចូលរួមផងដែរ[12]។ឯកសារខាងលើនេះ

[11] ឯកសារលេខ **E9/21.3** ឧបសម្ព័ន្ធទី៣ ភ្ជាប់ជាមួយនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "អង្គហេតុដែលមិនត្រូវបានជំទាស់" , ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ , កថាខណ្ឌទី៩៩៩។

[12] ឯកសារលេខ **E1/97.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីការជំនុំជម្រះក្តី,ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២,ចាប់ពីម៉ោង ០៩.៣០នាទីនិង៥០វិនាទី ដល់ម៉ោង០៩.៣៣នាទី និង៣៦វិនាទី, ពីម៉ោង ១១.៣៦នាទី និង២២វិនាទី ដល់ម៉ោង ១១.៤១នាទី និង៤៣វិនាទី [ដែលផ្តល់សក្ខីកម្មថា កិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមកាលពីឆ្នាំ១៩៧៤ ត្រូវបានធ្វើឡើងនៅក្នុងរដូវភ្លៀងក្នុងខែមិថុនា ឬ ខែកក្កដា ហើយដែល

បានផ្តល់នូវភាពស៊ីសង្វាក់គ្នាដ៏សំខាន់ ដែលបញ្ជាក់គាំទ្រចំពោះសក្ខីកម្មរបស់ ភី ភួន ដែលថា អៀង សារី និង ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមបក្ស នៅក្នុងខែមិថុនា ឆ្នាំ១៩៧៤។

១២. ជាចុងក្រោយបង្អស់ សារទូរលេខរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនៃស.រ.អា(ឯកសារលេខ២៦) ដែលរាយការណ៍រៀបរាប់ថា មាននាយទាហាននិងនាយទាហានរងចំនួន៨៧នាក់(របស់កងយោធពលខេមរៈជាតិ)នៃសាធារណៈរដ្ឋខ្មែរ ត្រូវបានសម្លាប់នៅប៉ោយប៉ែត កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៥ បន្ទាប់ពីការវិលត្រឡប់ពីប្រទេសថៃឡង់ មកកាន់មាតុប្រទេសវិញ និងថា មានបុគ្គលិករបស់កងយោធពលខេមរៈជាតិ ចំនួន២៤៧នាក់ដែលបានវិលត្រឡប់ពីប្រទេសថៃឡង់មកប៉ោយប៉ែតវិញ ត្រូវបានសម្លាប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៥ ។ ឯកសារនេះមានការជាប់ពាក់ព័ន្ធនៅក្នុងការបង្ហាញភស្តុតាងថា គោលនយោបាយរបស់ បកក ដែលផ្តោតមុខសញ្ញាទៅលើអតីតពួកមន្ត្រី និង ទាហាននៃរបបសាធារណៈរដ្ឋខ្មែរ។

១៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើថា ឯកសារទាំងឡាយដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធក សូមអោយដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងទទួលយកជាភស្តុតាង។ សំណើអោយការបកប្រែនូវសេចក្តីដកស្រង់មួយចំនួនដែលជាប់ទាក់ទងទៅនឹងឯកសារទាំងនេះ នឹងត្រូវបានដាក់ជូនទៅអង្គភាពគ្រប់គ្រងតុលាការ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

មានការចូលរួមដោយ អៀង សារី និង ខៀវ សំផន]។ ឯកសារលេខ **E3/24** កំណត់ហេតុស្តាប់ចម្លើយសាក្សី ភី ភួន, ចុះថ្ងៃទី៥ខែធ្នូ ឆ្នាំ២០០៧, ត្រង់លេខ ERN ជាភាសាអង់គ្លេស លេខ 00223581, ជាភាសាខ្មែរលេខ 00204068-69, ជាភាសាបារាំងលេខ 00503920-21។